**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១៤៣៩ ព.ណ..ក.វ.ជ

ថ្ងៃសុក្រ ៦ កើត ខែ ពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ពាណិជ្ជករនាំផលិតផលចូលទៅកាន់សហរដ្ឋអាមេរិក ពីកម្ពុជាឲ្យបានជ្រាបថា៖ កាលពីថ្ងៃសុក្រ ទី២៣ ខែមីនា ឆ្នាំ២០១៨ លោកប្រធានាធិបតីសហរដ្ឋអាមេរិក Donald Trump បានចុះហត្ថលេខាលើច្បាប់ស្តីពី H.R. 1625, the "Consolidated Appropriations Act, 2018," ដើម្បីបន្តឡើងវិញនៃប្រព័ន្ធអនុគ្រោះពន្ធទូទៅដោយភ្ជាប់ជាមួយការធ្វើប្រតិសកម្ម **ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០**។ ការបន្តឡើងវិញនៃការផ្តល់ប្រព័ន្ធអនុគ្រោះទូទៅនេះ នឹងចូលជាធរមានចាប់ **ពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៨** ហើយចំពោះអ្នកដែលបាននាំចូលទៅសហរដ្ឋអាមេរិកគិតចាប់ពី**ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨** អាចមកស្នើសុំដកប្រាក់ពន្ធដែលបានបង់រួចមកវិញបាន តាមការជូនដំណឹងរបស់តំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិក (USTR) ។ យោងទៅតាមការណែនាំរបស់អង្គភាពគយ និងការពារព្រំដែនសហរដ្ឋអាមេរិក (U.S. Customs and Border Protection (CBP)) បានបញ្ជាក់ថា រាល់ពាណិជ្ជករទាំងអស់ដែលប្រើ Special Program Indicator (SPI) កូដ("A"= All Developing Beneficiary Countries;) នឹងត្រូវទទួលប្រាក់ពន្ធដែលបានបង់ត្រលប់មកវិញដោយស្វ័យប្រវត្តិ។ ដោយឡែកចំពោះពាណិជ្ជករនាំផលិតផលចូលទៅកាន់សហរដ្ឋអាមេរិក ដែលមិនប្រើ SPI កូដ "A" អាចស្នើសុំប្រាក់ពន្ធមកវិញបាន តាមរយៈ U.S. Customs and Border Protection (CBP) ដោយត្រូវដាក់ពាក្យស្នើសុំដោយខ្លួនឯងតាមរយៈគេហទំព័រ https://www.cbp.gov/trade/priority-issues/trade-agreements/special-trade-legislation/generalized-system-preferences **ឲ្យបានមុនថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨**។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមពាណិជ្ជករ នាំផលិតផលចូលទៅកាន់សហរដ្ឋអាមេរិក ដែលមានបំណងដាក់ពាក្យស្នើសុំដកប្រាក់បង់ពន្ធត្រលប់មកវិញ តាមរយៈការធ្វើប្រតិសកម្ម ចំពោះការបន្តឡើងវិញនៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) មេត្តាចាត់ចែង និងរៀបចំដាក់ពាក្យស្នើសុំឲ្យបានមុន **ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨**។

**សម្គាល់៖** សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ FTA@dhs.gov.

**សូមអរគុណ !**

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469